ផាន់ ហ៊ឹង ហៅ ហន
--------

អាយុ ២០ ឆ្នាំ ។ ប្រុស ។ ខ្មែរ ។ នៅលីវ ។
កំណើត នៅភូមិព្រះវិហារ ឃុំតាំងក្រសាំង ស្រុកស្ទឹងត្រង់ កំពង់ចាម
នាទី យ.ជ កម្មកររោងចក្ររទេះភ្លើងភ្នំពេញ ។

តាំងពីតូចរហូតដល់ឆ្នាំ ៧២ រស់នៅរកស៊ីធ្វើស្រែជាមួយឪពុកម្ដាយ

១៩៧២ . ចូល ប.វ នៅកងតំបន់ ៤១ វ.ត ៣១៤ ។ ជា យ.ជ នៅកងតូច២ កងធំ ១ ។

១៩៧៣ . ចូលខ្មែរស តាមការអប់រំរបស់ ហេន ន.ប វរៈ ៤១៤ ។
ក្រោយពីបានចូលខ្មែរសមក ហន ត្រូវ ហេន យកពីកងឱ្យមកនៅជាមួយ ហេន ផ្ទាល់ ។ ហន ត្រូវ ហេន អប់រំពីរឿងលក្ខការណ៍កម្លាំងខ្មែរស ដែលកសាងបានជាបន្តបន្ទាប់ ។ នៅជាមួយ ហេន ហន បានលាក់ការណ៍សំងាត់របស់ ហេន ជាមេក្បត់និងជួយអប់រំបក្សពួកដែលនៅជាមួយគ្នាឱ្យជួយលាក់ការណ៍ពីរឿងនេះ ។

១៩៧៥ . ទៀងមក យ.ឆ ភូមិភាគឧត្ដរ ក.ព ១ វរៈ ៤១៤ នាទី យ.ជ ។

៥.៧៥ . ហន ចាត់តាំងឱ្យមកនៅរោងចក្ររទេះភ្លើងដើម្បីបង្កប់ស៊ីរូងផ្ទៃក្នុង ប.វ ។ មកនៅរោងចក្រ ហន មាននាទី យ.ជ កម្មកររោងចក្រ នៅក្រុមទៀងបង្គងទី ១ ។ ហន បានភ្ជាប់ខ្សែជាមួយ ហួន អនុក្រុម ទៀងបង្គងទី ១ ។ ជាបន្តបន្ទាប់ក្រោយពីភ្ជាប់ខ្សែមក ហួន បានអប់រំពីរឿងប្រមូលកម្លាំងខ្មែរសនៅក្នុងរោងចក្រ ។

១៧.៥.៧៦ . បានប្រជុំទទួលផែនការពី ហួន ជាមួយបក្សពួកពីរទៀង :-

១.- ប្រមូលកម្លាំង ។

២.- កំទេចមាស៊ីនក្រចៀង ។

៣.- កំទេចក្បាលរទេះភ្លើង ។

២៨.៧.៧៦ . ប្រជុំទទួលផែនការពីភាពម្តងទៀត ។

ក្នុងផែនការដែលបានទទួល ហន មានភារៈកំទេចមាស៊ីនក្រចៀង ជាមួយបក្សពួក ។ នៅក្នុងខែ ៩.៧៦ វេលាម៉ោង ៨ យប់ ។

ក្នុងខែ ៧ នេះដែលបានចូលទៅស៊ើបការណ៍ក្នុងរោងចក្រចំនួន២ដង យកមករាយការណ៍ឱ្យ ភាព ។

១៨.៨.៧៦ . អង្គការចាប់ព្រោះ ហួន - ថា - ខុម នាំគ្នារត់ចេញពីរោងចក្របាត់ទេ ទៅ ហន ក៏នាំបក្សពួកមាន ទ្រី និង រ៉ុន និយាយពីរឿងរបស់ ហួន រត់ទៅព្រៃថា អ.ក ចាប់បាន ហើយ ហួន ឆ្លើយដាក់ពួកដែលចូលដៃជាមួយ គេដែរ ។ ជាបន្តបន្ទាប់មកទៀត ហន និង បក្សពួកនេះតែងនាំគ្នា និយាយពីរឿងនេះ ហើយថាយើងមុខតែ អ.ក ចាប់ដែរហើយព្រោះយើង រួមចំណែកនៅក្នុងរឿងនេះដែរ ។

អំពីឪពុកម្តាយបង្កើត :

ឪពុកឈ្មោះ ផាន់ ចិត្រ អាយុ ៥២ ឆ្នាំ រស់ ។

ម្តាយ ឈ្មោះ ញ៉ាន់ ហាយ អាយុ ៤៧ ឆ្នាំ រស់ ។

របររកស៊ី បច្ចុប្បន្ន នៅភូមិភ្នំព្រះវិហារ ឃុំតាំងក្រសាំង ស្រុកដើងទីព្រ ខេត្ត កំពង់ចាម ។

អំពីបងប្អូនបង្កើត ៖

មានបងប្អូន ៥ នាក់ ។ ប្រុស ៣ ស្រី ២ ។

១.- ផាន់ អាន អាយុ ២២ ឆ្នាំ ប្រុស នៅលីវ ។

២.- ផាន់ ផល អាយុ ១៨ ឆ្នាំ ស្រី លីវ ។

៣.- ផាន់ លីម អាយុ ១៧ ឆ្នាំ ប្រុស លីវ ។

៤.- ផាន់ ភាច់ អាយុ ១៤ ឆ្នាំ ប្រុស លីវ ។

៥.- ផាន់ ផាន អាយុ ១១ ឆ្នាំ ស្រី លីវ ។

បងប្អូនទាំងអស់នៅជាមួយឪពុកម្តាយ ។